ធ៧-០១១-២៤៣ ប្រ.ក

# ប្រកាស
# ស្តីពី
# តម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រកបដោយតម្លាភាព យុត្តិធម៌ សមហេតុផល និងទទួលខុសត្រូវ។

**ប្រការ ២.-**

គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាថាការផ្សព្វផ្សាយពាណិជ្ជកម្ម និងពាក្យពេចន៍ក្នុងការផ្សព្វផ្សាយមានលក្ខណៈយុត្តិធម៌ ច្បាស់លាស់ មិនធ្វើឲ្យភាន់ច្រឡំ និងត្រូវធានាថាអតិថិជនបានទទួលព័ត៌មានច្បាស់លាស់អំពីផលិតផល និងសេវាកម្មទាំងឡាយ។

**ប្រការ ៣.-**

អតិថិជនត្រូវទទួលបានព័ត៌មានច្បាស់លាស់អំពីផលិតផល និងសេវាកម្មទាំងឡាយ នៅមុនពេល ឬក្នុងពេល ឬបន្ទាប់ពីពេលទទួលសេវាឥណទាន ដោយរួមមានបែបបទដំណើរការនៃឥណទាន លក្ខខណ្ឌអត្រាការប្រាក់ និងកម្រៃដែលជាបន្ទុករបស់អតិថិជន ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤.-**

អតិថិជនត្រូវទទួលបានព័ត៌មានជាមុន អំពីការប្រែប្រួលអត្រាការប្រាក់ កម្រៃ និងលក្ខខណ្ឌផ្សេងៗ។

**ប្រការ ៥.-**

ព័ត៌មានអតិថិជនត្រូវបានរក្សាទុកជាការសម្ងាត់ ហើយគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្តល់ជូនអតិថិជននូវប្រព័ន្ធធនាគារស្នូល និងប្រព័ន្ធទូទាត់ដែលមានសុវត្ថិភាព និងអាចជឿទុកចិត្តបាន។ ការរក្សាព័ត៌មានអតិថិជនជាសម្ងាត់មិនត្រូវអនុវត្តចំពោះការផ្តល់ព័ត៌មានអតិថិជនដល់ប្រព័ន្ធព័ត៌មានឥណទាននោះទេ។

**ប្រការ ៦.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

# តារាងព័ត៌មានសម្រាប់អតិថិជន

តារាងនេះសម្រាប់ផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ តារាងនេះកំណត់ចេញនូវថ្លៃដើមពេលបច្ចុប្បន្ន និងកម្រៃផ្សេងៗ សម្រាប់ឥណទានដែលទទួលបាន ហើយធនាគារអាចកែប្រែថ្លៃដើម និងកម្រៃទាំងនេះ ក្នុងករណីចាំបាច់។ សូមមេត្តាកត់សំគាល់ថាការផ្តល់នូវតារាងនេះមិនត្រូវចាត់ទុកថាជាការផ្តល់ឥណទានដល់អតិថិជនដោយធនាគារនោះទេ។

ឈ្មោះធនាគារ/និមិត្តសញ្ញា ឈ្មោះអ្នកសួរព័ត៌មាន ____________________

១. សាខា ____________________ ប្រភេទនៃខ្ចង់ឥណទាន ____________________

**ចំនួនឥណទាន និងការប្រាក់/កម្រៃផ្សេងៗរបស់ធនាគារ**

(គិតជាប្រាក់រៀល)

២. ចំនួនស្នើសុំ(ចំនួនប្រាក់ដើម) __________

៣. (ដក: ចំនួនត្រូវទូទាត់ក្នុងគ្រាទី១/ការប្រាក់បានបង់មុន) __________

៤. ចំនួនសុទ្ធដែលអតិថិជនបានទទួល __________

៥. អត្រាដែលស្នើសុំ ________ %ក្នុង១ឆ្នាំ

៦. អត្រាការប្រាក់មានប្រសិទ្ធភាព ________ %ក្នុង១ឆ្នាំ

៧. ការទូទាត់ប្រចាំខែ __________

៨. ចំនួនដងដែលត្រូវទូទាត់សង __________

៩. ការប្រាក់សរុប __________

១០.កម្រៃធ្វើប្រតិបត្តិការ __________

១១.កម្រៃផ្សេងៗរបស់ធនាគារ (សូមបញ្ជាក់ ប្រសិនបើមាន)

________________________________________ __________

១២. កម្រៃផ្សេងៗសរុប (ជួរទី១០ + ជួរទី១១) __________

១៣. ការប្រាក់សរុបបូកកម្រៃផ្សេងៗសរុប (ជួរទី៩ + ជួរទី១២) __________

១៤. សរុបចំនួននៅជំពាក់ (ជួរទី២ + (៣) ឬជួរទី៤ + ជួរទី១៣) __________

១៥. កាលបរិច្ឆេទនៃការចាប់ផ្តើមទូទាត់សង ______________

**<u>កម្រៃបន្ថែម</u>**

ធនាគារនឹងគិតកម្រៃសម្រាប់

| **(ក) ការទូទាត់សងឥណទានមុនពេលកំនត់** | ការទូទាត់សងដោយផ្នែក | ការទូទាត់សងពេញលេញ |
|---|---|---|
| ១៦.ប្រសិនបើសងក្នុងកំឡុងពេល | ______ឆ្នាំ | ______ឆ្នាំ |
| ១៧.ចំនួននៃការទូទាត់សងអប្បបរមាគឺ | ______ | |
| ១៨.កម្រៃលើការទូទាត់សងមុនពេលកំណត់ | ______ | ______ |
| ១៩.កម្រៃធ្វើប្រតិបត្តិការ | ______ | ______ |
| ២០.កំឡុងពេលជូនដំណឹងដែលតម្រូវ | ______ | ______ |

**(ខ) ការទូទាត់យឺតយ៉ាវតាមគ្រានិមួយៗ**

២១.ការប្រាក់ដែលត្រូវគិតគឺ ______%ក្នុង១ឆ្នាំ(សម្រាប់ចំនួនដែលជំពាក់)

២២.កម្រៃធ្វើប្រតិបត្តិការ ______

២៣.កម្រៃផ្សេងៗ ______________

**<u>កម្រៃសម្រាប់តតិយជន</u>**

២៤. ព័ត៌មានខាងលើ មិនរាប់បញ្ចូលកម្រៃសម្រាប់តតិយជន មានដូចជាតែមប្រ៊ី កម្រៃផ្នែកច្បាប់ កម្រៃលើការវាយតំលៃបុព្វលាភ ធានារ៉ាប់រង។ល។ សូមមេត្តាត្រួតពិនិត្យជាមួយគូរភាគីខាងលើស្តីពីកម្រៃទាំងឡាយ។

**គោលនយោបាយធានារ៉ាប់រងដែលទាមទារឲ្យមាន**

---

មន្ត្រីដែលមានវត្តមាន ______________ ហត្ថលេខា ______________

កាលបរិច្ឆេទ ______________